# សន្និសីទថ្នាក់ជាតិស្តីពី ការអនុវត្តល្អបំផុតក្នុងវិជ្ជាជីវៈឆ្មប

(National Conference on the Best Practice in Midwifery)

**សូមគោរពជូន**

**លោកស្រី ឆាយ ស្វេងជាអាធី**

**កម្មវត្ថុ៖** សូមគោរពអញ្ជើញធ្វើជាវាគ្មិន (Speaker) សម្រាប់សន្និសីទថ្នាក់ជាតិស្តីពី **ការអនុវត្តល្អបំផុតក្នុងវិជ្ជាជីវៈ** (National Conference on the Best Practice in Midwifery)។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **លោកស្រី** មេត្តាជ្រាបថា សាកលវិទ្យាល័យ អន្តរជាតិ ក្រោមកិច្ចគាំទ្ររបស់កម្មវិធី Erasmus+ របស់សហគមន៍អឺរ៉ុប (EU) នឹងរៀបចំសន្និសីទថ្នាក់ជាតិស្តីពី **"ការអនុវត្តល្អបំផុតក្នុងវិជ្ជាជីវៈឆ្មប"** (National Conference on the Best Practice in Midwifery) នៅរសៀលថ្ងៃសៅរ៍ ទី០១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១:00 - ៥:២០ នាទី ទីតាំងសាកលវិទ្យាល័យ អន្តរជាតិ។

សន្និសីទថ្នាក់ជាតិស្តីពី ការអនុវត្តល្អបំផុតក្នុងវិជ្ជាជីវៈឆ្មប នេះមានគោលបំណងបណ្តុះបណ្តាលនិងផ្សព្វផ្សាយនូវចំណេះដឹងជាន់ខ្ពស់និងថ្មីៗបំពេញបន្ថែមពាក់ព័ន្ធនឹងជំនាញឆ្មប ជូនដល់បុគ្គលិកសុខាភិបាល ទាំងវិស័យរដ្ឋនិងឯកជន កំពុងបំពេញការងារលើផ្នែកនេះនៅទូទាំងប្រទេសកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកស្រី** មេត្តាចូលរួមធ្វើជាវាគ្មិននៅក្នុងសន្និសីទ តាមកម្មវិធីដែលមានជូនភ្ជាប់មកជាមួយនេះដោយក្តីអនុគ្រោះ។

សូម **លោកស្រី** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្មគ្រអំពីខ្ញុំ។

ថ្ងៃ សុក្រ ៤ កើត ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២២

**សាកលវិទ្យាធិការរង**

**ងេត បារ៉ុម**

**បញ្ជាក់៖**

១. សូមផ្ញើ File ប្រធានបទ អោយបានមុនថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២

២. ភ្ជាប់ជាមួយកម្មវិធីសិក្ខាសាលា

៣. ទំនាក់ទំនង៖ ០១១ ២០៨ ៩៨១ (Telegram)